ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងពាណិជ្ជកម្ម
លេខ ០៤០ ព.ណ.

# ប្រកាស
# ស្តីពី
# ទម្រង់ និងបែបបទនៃការដកហូត
# ម្ហូបអាហារគ្មានសុវត្ថិភាព ឬមិនអនុលោមតាមបទប្បញ្ញត្តិបច្ចេកទេស

## រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៨/៩២៥ ចុះថ្ងៃទី៦ ខែកញ្ញា ឆ្នាំ២០១៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៣២០/៤២១ ចុះថ្ងៃទី៣០ ខែមីនា ឆ្នាំ២០២០ ស្តីពីការតែងតាំងនិងកែសម្រួលសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៦ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងពាណិជ្ជកម្ម
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦២២/០០៦ ចុះថ្ងៃទី៨ ខែមិថុនា ឆ្នាំ២០២២ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីសុវត្ថិភាពម្ហូបអាហារ
- បានឃើញអនុក្រឹត្យលេខ៣៨ អនក្រ.បក ចុះថ្ងៃទី១៦ ខែមីនា ឆ្នាំ២០២០ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងពាណិជ្ជកម្ម
- បានឃើញអនុក្រឹត្យលេខ១៣ អនក្រ.បក ចុះថ្ងៃទី៦ ខែមករា ឆ្នាំ២០២៣ ស្តីពីលក្ខខណ្ឌ បែបបទ និងនីតិវិធីនៃការអង្កេតដាន និងការដកហូតម្ហូបអាហារ
- យោងតាមតម្រូវការចាំបាច់របស់ក្រសួងពាណិជ្ជកម្ម



ឡូត៍លេខ ១៩-៦១ មហាវិថីសហព័ន្ធរុស្ស៊ី ភូមិទឹកថ្លា សង្កាត់ទឹកថ្លា ខណ្ឌសែនសុខ រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា ទូរស័ព្ទ / ទូរសារៈ (៨៥៥)-២៣ ៨៦៦ ៤៦៩
Lot 19-61, Russian Federation Blvd, Phum Teuk Thla, Sangkat Teuk Thla, Khan Sen Sok, Phnom Penh, Kingdom of CAMBODIA Phone/Facsimile: (855)-23 866 469

## សម្រេច

**ប្រការ១.-**

ប្រកាសនេះកំណត់អំពីទម្រង់ និងបែបបទនៃការដកហូតម្ហូបអាហារគ្មានសុវត្ថិភាព ឬមិនអនុលោមតាមបទប្បញ្ញត្តិបច្ចេកទេស ក្នុងគោលបំណងបង្ការផលប៉ះពាល់ដល់សុខភាព និងផលប្រយោជន៍អ្នកប្រើប្រាស់។

**ប្រការ២.-**

ប្រកាសនេះមានវិសាលភាពអនុវត្តចំពោះផលិតផលម្ហូបអាហារគ្រប់ប្រភេទដែលត្រូវបានជូនដំណឹងថាគ្មានសុវត្ថិភាព ឬមិនអនុលោមតាមបទប្បញ្ញត្តិបច្ចេកទេស ដែលតម្រូវឱ្យដកហូតចេញពីទីផ្សារនិង/ឬពីអ្នកប្រើប្រាស់ក្នុងព្រះរាជាណាចក្រកម្ពុជា។

**ប្រការ៣.-**

វាក្យសព្ទសំខាន់ៗ ដែលប្រើក្នុងប្រកាសនេះ មានអត្ថន័យដូចខាងក្រោម៖

១. **បទប្បញ្ញត្តិបច្ចេកទេស** សំដៅដល់ឯកសារដែលចែងអំពីចរិតលក្ខណៈផលិតផល ឬដំណើរការពាក់ព័ន្ធនិងវិធីសាស្ត្រផលិតកម្ម ដោយរួមបញ្ចូលទាំងបញ្ញត្តិរដ្ឋបាលដែលអាចអនុវត្តបាន ដែលការអនុលោមមានលក្ខណៈបញ្ជា។ បទប្បញ្ញត្តិបច្ចេកទេសអាចរួមបញ្ចូល ឬប្រើប្រាស់សម្រាប់តែការតម្រូវផ្នែក វាក្យសព្ទ និមិត្តសញ្ញា ការវេចខ្ចប់ ការធ្វើសញ្ញាសម្គាល់ ឬការធ្វើស្លាកសញ្ញា ដែលអនុវត្តទៅលើផលិតផល ដំណើរការ ឬវិធីសាស្ត្រផលិតកម្ម។

២. **ប្រតិបត្តិករអាជីវកម្មម្ហូបអាហារ** សំដៅដល់ម្ចាស់អាជីវកម្មម្ហូបអាហារ ឬបុគ្គលដែលត្រូវបានប្រគល់សិទ្ធិក្នុងការប្រតិបត្តិអាជីវកម្មម្ហូបអាហារ ឬបុគ្គលទទួលខុសត្រូវលើអាជីវកម្មម្ហូបអាហារដោយអនុលោមតាមច្បាប់និងលិខិតបទដ្ឋានគតិយុត្តនៃព្រះរាជាណាចក្រកម្ពុជា ដូចជាផលិតករ អ្នកកែច្នៃ អ្នកវេចខ្ចប់ អាជីវករលក់ដុំ អាជីវករចែកចាយ និងអាជីវករលក់រាយជាដើម។

៣. **ការដកហូតម្ហូបអាហារ** សំដៅដល់ការអនុវត្តសកម្មភាពនានាដែលពាក់ព័ន្ធនឹងការប្រមូលមកវិញនូវម្ហូបអាហារដែលគ្មានសុវត្ថិភាព ឬមិនអនុលោមតាមបទប្បញ្ញត្តិបច្ចេកទេស ដែលចរាចរនៅតាមបណ្ដាទីផ្សារ និងនៅតាមដំណាក់កាលផ្សេងៗ នៃខ្សែច្រវាក់ម្ហូបអាហាររួមទាំងការចែកចាយ ការស្តុកទុក ការផ្តល់សេវាម្ហូបអាហារ ការផ្តល់ជាអំណោយ ការវេចខ្ចប់ និងការកែច្នៃ ក្នុងគោលបំណងការពារសុខភាពនិងផលប្រយោជន៍អ្នកប្រើប្រាស់។

៤. **ម្ហូបអាហារគ្មានសុវត្ថិភាព** សំដៅដល់ម្ហូបអាហារដែលបង្កគ្រោះថ្នាក់ដល់អ្នកប្រើប្រាស់នៅពេលដែលត្រូវបានយកទៅធ្វើការរៀបចំ ឬបរិភោគស្របតាមកម្មវត្ថុប្រើប្រាស់របស់ម្ហូបអាហារនោះ។

៥. **ម្ហូបអាហារមិនអនុលោមតាមបទប្បញ្ញត្តិបច្ចេកទេស** សំដៅដល់ម្ហូបអាហារដែលមិនអនុលោមតាមឯកសារដែលចែងអំពីចរិតលក្ខណៈផលិតផល ឬដំណើរការពាក់ព័ន្ធនឹងវិធីសាស្ត្រផលិតកម្មបញ្ញត្តិរដ្ឋបាលដែលអាចអនុវត្តបាន ដែលការអនុលោមមានលក្ខណៈបញ្ជា និងរួមទាំងមិនអនុលោមតាមនិមិត្តសញ្ញា ការវេចខ្ចប់ ការធ្វើសញ្ញាសម្គាល់ ឬការធ្វើស្លាកសញ្ញា ដែលអនុវត្តទៅលើផលិតផល ដំណើរការ ឬវិធីសាស្ត្រផលិតកម្ម។

**ប្រការ៤.-**

រាល់ប្រតិបត្តិករអាជីវកម្មម្ហូបអាហារ ត្រូវអនុវត្តការដកហូតម្ហូបអាហារមកវិញ បន្ទាប់ពីបានដឹងឬទទួលព័ត៌មានថាម្ហូបអាហាររបស់ខ្លួនគ្មានសុវត្ថិភាព ឬមិនអនុលោមតាមបទប្បញ្ញត្តិបច្ចេកទេស ឬបន្ទាប់ពីទទួលបានការបញ្ជាពីក្រសួងពាណិជ្ជកម្មឱ្យដកហូតម្ហូបអាហារមកវិញ។

រាល់ការដកហូតម្ហូបអាហារមកវិញ ត្រូវអនុលោមទៅតាមបញ្ញត្តិ ដូចបានកំណត់នៅក្នុងមាត្រា៨ មាត្រា១០ មាត្រា១១ និងមាត្រា១២ នៃអនុក្រឹត្យស្ដីពីលក្ខខណ្ឌ បែបបទ និងនីតិវិធីនៃការអង្កេតដាននិងការដកហូតម្ហូបអាហារ។

**ប្រការ៥.-**

ប្រតិបត្តិករអាជីវកម្មម្ហូបអាហារ ត្រូវផ្តល់ព័ត៌មានមកអគ្គនាយកដ្ឋានការពារអ្នកប្រើប្រាស់ កិច្ចការប្រកួតប្រជែង និងបង្ក្រាបការក្លែងបន្លំ «ក.ប.ប.» នៃក្រសួងពាណិជ្ជកម្ម ជាលាយលក្ខណ៍អក្សរ រួមទាំងព័ត៌មានលម្អិតពីម្ហូបអាហារណាមួយដែលត្រូវដកហូតក្រោមការទទួលខុសត្រូវរបស់ខ្លួន ស្របតាមលិខិតបទដ្ឋានគតិយុត្តជាធរមាន។ ទម្រង់ស្ដីពីព័ត៌មានតម្រូវនានាពាក់ព័ន្ធនឹងការដកហូតម្ហូបអាហារ មានភ្ជាប់ក្នុងឧបសម្ព័ន្ធ១ នៃប្រកាសនេះ។

**ប្រការ៦.-**

អគ្គនាយកដ្ឋាន ក.ប.ប. ត្រូវពិនិត្យ និងវាយតម្លៃលើព័ត៌មានដែលទទួលបានពីប្រតិបត្តិករអាជីវកម្មម្ហូបអាហារ និងត្រូវឆ្លើយតបភ្លាមៗ នូវវិធានការសមស្រប ដោយផ្អែកតាមការវាយតម្លៃហានិភ័យដែលបានចាត់ថ្នាក់នៅក្នុងមាត្រា៩ នៃអនុក្រឹត្យស្ដីពីលក្ខខណ្ឌ បែបបទ និងនីតិវិធីនៃការអង្កេតដាន និងការដកហូតម្ហូបអាហារ។

ប្រតិបត្តិករអាជីវកម្មម្ហូបអាហារ អាចចាត់តំណាងដើម្បីធ្វើការប្រាស្រ័យទាក់ទងជាមួយអគ្គនាយកដ្ឋាន ក.ប.ប. ចាប់តាំងពីដំណាក់កាលដំបូងនៃប្រតិបត្តិការ រហូតដល់ការដកហូតម្ហូបអាហារនោះត្រូវបានបញ្ចប់។

**ប្រការ៧.-**

អគ្គនាយកដ្ឋាន ក.ប.ប. និង/ឬប្រតិបត្តិករអាជីវកម្មម្ហូបអាហារ ត្រូវចេញសារព្រមានអំពីផលប៉ះពាល់ដល់សុខភាពដោយសារម្ហូបអាហារដែលត្រូវដកហូតនេះជាសាធារណៈ តាមគ្រប់មធ្យោបាយ។ ទម្រង់សេចក្តីប្រកាសព័ត៌មានស្ដីពីផលិតផលម្ហូបអាហារអាចមានភ្ជាក់ងារបង្កគ្រោះថ្នាក់ចំពោះសុខភាព ដូចមានក្នុងឧបសម្ព័ន្ធ២នៃប្រកាសនេះ។

**ប្រការ៨.-**

ប្រតិបត្តិករអាជីវកម្មម្ហូបអាហារ ត្រូវរៀបចំឱ្យមានជាស្រេចនូវនីតិវិធីប្រតិបត្តិការស្តង់ដារសម្រាប់ការដកហូតម្ហូបអាហារ ដើម្បីធានាដល់ដំណើរការនៃការដកហូតម្ហូបអាហារមកវិញមានប្រសិទ្ធភាព។

**ប្រការ៩.-**

ប្រតិបត្តិករអាជីវកម្មម្ហូបអាហារ ត្រូវផ្សព្វផ្សាយព័ត៌មានជាសាធារណៈនូវម្ហូបអាហារដែលត្រូវដកហូតនៅក្រោមការទទួលខុសត្រូវរបស់ខ្លួន។ ទម្រង់ស្ដីពីការផ្សព្វផ្សាយព័ត៌មានជាសាធារណៈនូវម្ហូបអាហារដែលត្រូវដកហូត ដូចមានក្នុងឧបសម្ព័ន្ធ៣នៃប្រកាសនេះ។

**ប្រការ១០.-**

ប្រតិបត្តិករអាជីវកម្មម្ហូបអាហារ ត្រូវផ្ញើរបាយការណ៍ពាក់ព័ន្ធនឹងការដកហូតម្ហូបអាហារនោះមកអគ្គនាយកដ្ឋាន ក.ប.ប.។ ទម្រង់ស្តីពីរបាយការណ៍ពាក់ព័ន្ធនឹងការដកហូតម្ហូបអាហារ ដូចមានក្នុងឧបសម្ព័ន្ធ៤ នៃប្រកាសនេះ។

**ប្រការ១១.-**

នៅពេលការដកហូតម្ហូបអាហារគ្មានសុវត្ថិភាព ឬមិនអនុលោមតាមបទប្បញ្ញត្តិបច្ចេកទេសត្រូវបញ្ចប់ ប្រតិបត្តិករអាជីវកម្មម្ហូបអាហារត្រូវ៖

ក- ផ្ញើលិខិតសុំបញ្ចប់ និងរបាយការណ៍ពាក់ព័ន្ធផ្សេងៗ មកអគ្គនាយកដ្ឋាន ក.ប.ប. តាមរយៈលិខិតសារអេឡិចត្រូនិក ទូរសារ ទូរស័ព្ទ ឬតាមមធ្យោបាយផ្សេងៗទៀត ដើម្បីពិនិត្យសម្រេច។

ខ- បង្ហាញជូនអគ្គនាយកដ្ឋាន ក.ប.ប. អំពីវិធានការក្នុងការកែតម្រូវ និងការការពារមិនឱ្យករណីដដែលកើតឡើងម្តងទៀត។

អគ្គនាយកដ្ឋាន ក.ប.ប. ត្រូវពិនិត្យ វាយតម្លៃលើរបាយការណ៍ដែលទទួលបានពីប្រតិបត្តិករអាជីវកម្មម្ហូបអាហារ និងធ្វើសេចក្តីសន្និដ្ឋានពាក់ព័ន្ធនឹងវិធានការដែលត្រូវអនុវត្តបន្តទៀត។ នៅពេលអគ្គនាយកដ្ឋាន ក.ប.ប. យល់ឃើញថាគ្រប់គ្រាន់ សមស្រប និងសម្រេចឯកភាពចំពោះប្រសិទ្ធភាពនៃការដកហូតម្ហូបអាហារនេះហើយ អគ្គនាយកដ្ឋាន ក.ប.ប. ត្រូវចេញសេចក្តីប្រកាសបញ្ចប់ការដកហូតម្ហូបអាហារជាផ្លូវការ។

**ប្រការ១២.-**

បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងប្រកាសនេះ ត្រូវទុកជានិរាករណ៍។

**ប្រការ១៣.-**

នាយកខុទ្ទកាល័យ ប្រតិភូរាជរដ្ឋាភិបាលកម្ពុជា ទទួលបន្ទុកជាអគ្គនាយកនៃអគ្គនាយកដ្ឋានការពារអ្នកប្រើប្រាស់ កិច្ចការប្រកួតប្រជែង និងបង្ក្រាបការក្លែងបន្លំ អគ្គនាយក អគ្គាធិការ និងប្រធានគ្រប់អង្គភាពចំណុះក្រសួងពាណិជ្ជកម្ម ត្រូវទទួលបន្ទុកអនុវត្តប្រកាសនេះតាមភារកិច្ចរៀងៗខ្លួន ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ថ្ងៃចន្ទ ៣កើត ខែជេស្ឋ ឆ្នាំខាល ចត្វាស័ក ព.ស.២៥៦៦

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី២២ ខែឧសភា ឆ្នាំ២០២៣

**រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម**

**ប៉ាន-សូរស័ក្តិ**

**កន្លែងទទួល:**

- ទីស្តីការគណៈរដ្ឋមន្ត្រី
- ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- ក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍
- ក្រសួងទេសចរណ៍
- ក្រសួងសុខាភិបាល
- ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ
- ខុទ្ទកាល័យសម្តេចអគ្គមហាសេនាបតីតេជោនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យសម្តេច ឯកឧត្តម លោកជំទាវឧបនាយករដ្ឋមន្ត្រី
- ដូចប្រការ១៣
- រាជកិច្ច
- ឯកសារ កាលប្បវត្តិ

**ឧបសម្ព័ន្ធ១នៃប្រកាសលេខ.......................................ចុះថ្ងៃទី........ខែ...........ឆ្នាំ២០២៣**

## ព័ត៌មានស្តីពីការដកហូតម្ហូបអាហារដោយប្រតិបត្តិករអាជីវកម្មម្ហូបអាហារ

សមត្ថកិច្ចជូនដំណឹង៖ អគ្គនាយកដ្ឋានការពារអ្នកប្រើប្រាស់ កិច្ចការប្រកួតប្រជែង និងបង្ក្រាបការក្លែងបន្លំ

..........................................................................................................................................

កាលបរិច្ឆេទ៖.............................................................................................................................

## ហេតុផលនៃការដកហូតម្ហូបអាហារ

ហេតុផលនៃការដកហូតម្ហូបអាហារ (ការបរិយាយលម្អិត).......................................................................

..........................................................................................................................................

..........................................................................................................................................

វិធានការដែលត្រូវដាក់ចេញ៖.......................................................................................................

វិធីសាស្ត្របោះចោល/កម្ទេចចោល៖.................................................................................................

ការរកឃើញបញ្ហាដែលត្រូវដកហូត ៖...............................................................................................

ជំងឺ/ការរងរបួស៖.......................................................................................................................

## ព័ត៌មានអំពីក្រុមហ៊ុន

នាមករណ៍ក្រុមហ៊ុន៖....................................................................................................................

អាសយដ្ឋានក្រុមហ៊ុន៖..................................................................................................................

គោត្តនាម និងនាមអ្នកសម្របសម្រួលរបស់ក្រុមហ៊ុន៖.........................................................................

ទូរស័ព្ទទំនាក់ទំនង/សារអេឡិចត្រូនិក៖...........................................................................................

ទូរស័ព្ទទំនាក់ទំនងជាសាធារណៈ៖..................................................................................................

## ព័ត៌មានលម្អិតអំពីផលិតផល

ប្រភេទម្ហូបអាហារ៖.....................................................................................................................

ឈ្មោះផលិតផល៖........................................................................................................................

ការលម្អិតពីសម្បកវេចខ្ចប់៖..........................................................................................................

កាលបរិច្ឆេទប្រើប្រាស់៖................................................................................................................

លេខឡូត៍/លេខកូដ៖.....................................................................................................................

ប្រទេសប្រភព៖...........................................................................................................................

## ការចែកចាយ

ចំនួនផលិតផលដែលបាននាំចូល/បានផលិត៖......................................................................................

ចំនួនផលិតផលដែលនៅសល់ក្នុងឃ្លាំង៖.........................................................................................

ប្រភេទហាងចែកចាយ៖................................................................................................................

កាលបរិច្ឆេទចាប់ផ្តើមចែកចាយផលិតផល៖.....................................................................................

ចែកចាយទីណាខ្លះ៖.....................................................................................................................

## ផែនការស្តីពីមធ្យោបាយទំនាក់ទំនង

ព័ត៌មានស្តីពីការដកហូតម្ហូបអាហារត្រូវបានទំនាក់ទំនងទៅអ្នកប្រើប្រាស់តាម៖.........................................

..........................................................................................................................................

ព័ត៌មានផ្សេងៗ៖.........................................................................................................................

**ឧបសម្ព័ន្ធ២នៃប្រកាសលេខ..........................................ចុះថ្ងៃទី.........ខែ............ឆ្នាំ២០២៣**

# សេចក្តីប្រកាសព័ត៌មាន
# ស្តីពី
# ផលិតផលម្ហូបអាហារអាចមានភ្នាក់ងារបង្កគ្រោះថ្នាក់ចំពោះសុខភាព

រាជធានីភ្នំពេញថ្ងៃទី.......ខែ.........ឆ្នាំ............អគ្គនាយកដ្ឋានការពារអ្នកប្រើប្រាស់ កិច្ចការប្រកួតប្រជែង និងបង្ក្រាបការក្លែងបន្លំ «ក.ប.ប.» និងក្រុមហ៊ុន.......................................សូមជូនដំណឹងដល់សាធារណជនទាំងអស់ជ្រាបថាផលិតផលម្ហូបអាហារ.......................................អាចមានការចម្លងចូលនូវ.......................................។ អាស្រ័យហេតុនេះ សូមសាធារណជនកុំប្រើផលិតផលម្ហូបអាហារ ដែលមាន៖

ក. អត្តសញ្ញាណ៖

១. ផលិតផលឈ្មោះ.........................

២. ទំហំ/ប្រភេទសម្បកវេចខ្ចប់...............................

៣. លេខកូដផលិតផល..........................

៤. លេខឡូត៍...................................

៥. កាលបរិច្ឆេទផលិត...................................កាលបរិច្ឆេទផុតកំណត់ប្រើប្រាស់........................

៦. ផ្សេងទៀត............................................។

ខ. ព័ត៌មានពាក់ព័ន្ធនឹងផលិតផលម្ហូបអាហារខាងលើ៖

១. ចំនួនអ្នករងគ្រោះដែលបានរាយការណ៍.............. (មិនមាន/មាន)

២. ភ្នាក់ងារបង្កគ្រោះ (ប្រភេទ និងឈ្មោះ).....................................

៣. សភាពផលិតផលបន្ទាប់ពីមានការចម្លង: (អាចមើលទៅមិនមានប្រែប្រួល ឬប្រែប្រួល ក្លិន រូបរាង ពណ៌)

..........................................................................................................................................

៤. រោគសញ្ញា: ..........................................................................................................។

ការទទួលទានម្ហូបអាហារដែលមានភ្នាក់ងារបង្កគ្រោះប្រភេទ ......................... (ឈ្មោះភ្នាក់ងារបង្កគ្រោះ) ...................................នេះអាចបណ្តាលឱ្យឈឺ និងប៉ះពាល់ដល់សុខភាព ដូចជា..............ដែលជាជំងឺដែលបណ្តាលមកពីម្ហូបអាហារ។ ចំពោះកុមារតូច មនុស្សចាស់ និងអ្នកដែលមានប្រព័ន្ធការពាររាងកាយចុះខ្សោយ អាចបណ្តាលឱ្យមានគ្រោះថ្នាក់ធ្ងន់ធ្ងរ ហើយជួនកាលអាចស្លាប់បាន។

បច្ចុប្បន្នផលិតផលទាំងនេះបាន និងកំពុងចែកចាយនៅក្នុងទីផ្សារនៃព្រះរាជាណាចក្រកម្ពុជា ហើយក្រុមហ៊ុន និងអ្នកពាក់ព័ន្ធផ្សេងទៀតកំពុងប្រមូលផលិតផលម្ហូបអាហារទាំងនេះចេញពីទីផ្សារ និងពីអ្នកប្រើប្រាស់។ ជាមួយគ្នានេះ អគ្គនាយកដ្ឋាន ក.ប.ប. កំពុងត្រួតពិនិត្យ តាមដានលើដំណើរការនៃការដកហូតផលិតផលទាំងនេះឱ្យមានប្រសិទ្ធភាព។

សម្រាប់ព័ត៌មានបន្ថែម សូមទំនាក់ទំនង៖

- អគ្គនាយកដ្ឋាន ក.ប.ប. ទូរស័ព្ទលេខ.............................រៀងរាល់ម៉ោងធ្វើការ
- ក្រុមហ៊ុនឈ្មោះ...................................ទូរស័ព្ទលេខ................................

សម្រាប់ព័ត៌មានអំពីសារធាតុបង្កគ្រោះ...................................សូមចូលទៅកាន់គេហទំព័រខាងក្រោម នៅគេហទំព័រភ្ជាប់.....................................................។

**ឧបសម្ព័ន្ធ៣នៃប្រកាសលេខ.........................................ចុះថ្ងៃទី.........ខែ...........ឆ្នាំ២០២៣**

## ទម្រង់ខិត្តប័ណ្ណផ្សព្វផ្សាយព័ត៌មាន

| | |
|---|---|
| - នាមករណ៍ក្រុមហ៊ុន៖............................................................<br>- ឈ្មោះផលិតផល/បរិយាយ៖.................................... ...............<br>- ទំហំសម្បកវេចខ្ចប់៖............................................ ...............<br>- បាច់/ឡូត៍៖........................................................ ............... | រូបភាពរបស់ផលិតផល<br>ម្ហូបអាហារ |

បរិយាយលម្អិតអំពីកំហុសរបស់ផលិតផលម្ហូបអាហារនោះ៖...............................................................

.....................................................................................................................................

.....................................................................................................................................

.....................................................................................................................................

.....................................................................................................................................

.....................................................................................................................................

ព័ត៌មានចំពោះអ្នកប្រើប្រាស់៖

.....................................................................................................................................

.....................................................................................................................................

.....................................................................................................................................

.....................................................................................................................................

.....................................................................................................................................

អាសយដ្ឋានរបស់ក្រុមហ៊ុន និងព័ត៌មានទំនាក់ទំនងលម្អិត៖.........................................................

.....................................................................................................................................

.....................................................................................................................................

.....................................................................................................................................

.....................................................................................................................................

ការសន្យារបស់ក្រុមហ៊ុន៖..........................................................................................................

.....................................................................................................................................

.....................................................................................................................................

.....................................................................................................................................

.....................................................................................................................................

.....................................................................................................................................

ផ្សេងៗ៖.......................................................................................................................................

.....................................................................................................................................

.....................................................................................................................................

.....................................................................................................................................

.....................................................................................................................................

.....................................................................................................................................

.....................................................................................................................................

**ឧបសម្ព័ន្ធ៤នៃប្រកាសលេខ.........................................ចុះថ្ងៃទី........ខែ...........ឆ្នាំ២០២៣**

# របាយការណ៍ស្តីពីការដកហូតម្ហូបអាហារ

## I. ព័ត៌មានពីក្រុមហ៊ុន

- នាមករណ៍ក្រុមហ៊ុន៖..........................................................................................................
- អាសយដ្ឋានក្រុមហ៊ុន៖.......................................................................................... ........
- ទូរសារ៖............................................................................................................... ......
- សារអេឡិចត្រូនិក៖............................................................................................. .........
- ទីតាំងការិយាល័យក្រុមហ៊ុន៖.............................................................................. ........
- ទីតាំងផលិត៖..................................................................................................... ........
- ទំនាក់ទំនងជាមួយស្ថាប័នពាក់ព័ន្ធ៖..................................................................... ........
- ការផ្សព្វផ្សាយព័ត៌មានអំពីម្ហូបអាហារប៉ះពាល់នេះ៖............................................... ...........

...................................................................................................................................... .........។

## II. តំណាងអ្នកសម្របសម្រួលរបស់ក្រុមហ៊ុនក្នុងការដកហូតម្ហូបអាហារ

- គោត្តនាម និងនាមអ្នកទំនាក់ទំនងរបស់ក្រុមហ៊ុន៖................................................... ..........
- ទូរស័ព្ទលេខ៖..................................................................................................... ........

## III. អ្នកទំនាក់ទំនងជាមួយអ្នកប្រើប្រាស់

- គោត្តនាម និងនាមអ្នកទំនាក់ទំនង៖.......................................................................................
- ទូរស័ព្ទលេខ៖..................................................................................................... ........

## IV. ព័ត៌មានម្ចាស់ពាណិជ្ជនាម

- គោត្តនាម និងនាមម្ចាស់ពាណិជ្ជនាម៖.................................................................. ........
- មានទំនាក់ទំនងជាមួយម្ចាស់ពាណិជ្ជនាមឬទេ?........................................................ ........
- អ្នកណាជាអ្នកទទួលខុសត្រូវដំបូងគេ៖...................................................................................

## V. ផលិតផលម្ហូបអាហារ

- ចំនួនម្ហូបអាហារដែលត្រូវដកហូត៖........................................................................ ........

## VI. ព័ត៌មានម្ហូបអាហារ

- ឈ្មោះផលិតផល៖.............................................................................................. ........
- ប្រភេទម្ហូបអាហារ៖............................................................................................ ........
- កាលបរិច្ឆេទប្រើប្រាស់៖........................................................................................ ........
- ទម្រង់រូបរាងសម្បកវេចខ្ចប់៖.....................................................................................
- លេខបាច់/ឡូត៍/លេខកូដ៖.................................................................................... ........
- ទំហំ៖......................................................ទម្ងន់ក្នុងមួយកញ្ចប់៖.............................. ........
- បរិយាយពីសម្បកវេចខ្ចប់ម្ហូបអាហារ៖.................................................................... ........
- រូបភាពផលិតផលម្ហូបអាហារ៖............................................................................. .......

## VII. ព័ត៌មានពីការនាំចូល

- បាននាំចូល៖........................................................................................................ ........
- ប្រទេសដើម៖....................................................................................................... ........
- កាលបរិច្ឆេទនាំចូល៖............................................................................................ .......
- លេខគយមាត់ច្រកនាំចូល៖.................................................................................... ........

## VIII. ព័ត៌មានពីក្រុមហ៊ុននាំចូល

- គោត្តនាម និងនាមអ្នកនាំចូល៖............................................................................. ........
- អាសយដ្ឋានអ្នកនាំចូល៖........................................................................................ ......

IX. **ព័ត៌មានពីអ្នកផលិតម្ហូបអាហារ**

- គោត្តនាម និងនាមអ្នកផលិត៖.............................................................................. ........
- អាសយដ្ឋានអ្នកផលិត៖...................................................................................... ........

X. **ព័ត៌មានពីក្រុមហ៊ុនផ្គត់ផ្គង់**

- គោត្តនាម និងនាមអ្នកផ្គត់ផ្គង់៖....................................................................... .......
- អាសយដ្ឋានអ្នកផ្គត់ផ្គង់៖.................................................................................. .......

XI. **ការចែកចាយម្ហូបអាហារ**

- វិធីសាស្ត្រចែកចាយ៖........................................................................................ ........
- កន្លែងក្រុមហ៊ុនចែកចាយផ្ទាល់/លក់រាយ៖.......................................................... ........
- ការជូនដំណឹងជាលាយលក្ខណ៍អក្សររបស់អ្នកចែកចាយ៖.............................................. ........
- ចំនួនម្ហូបអាហារប៉ះពាល់បានផលិត/នាំចូល៖......................................................... ........
- ចំនួនម្ហូបអាហារប៉ះពាល់មិនទាន់បានចែកចាយ៖..................................................... ........
- រយៈពេលម្ហូបអាហារប៉ះពាល់បានចូលដល់ទីផ្សារ៖.................................................... ........
- ម្ហូបអាហារបាននាំចេញទៅប្រទេសក្រៅទេ?៖............................................................ ........
- ប្រទេសដែលបាននាំចេញទៅនិងចំនួន៖.........................................................................

  ..........................................................................................................................
- ការជូនដំណឹងជាលាយលក្ខណ៍អក្សរ៖.........................................................................

XII. **ហេតុផលនៃការដកហូតម្ហូបអាហារ**

- បរិយាយពីហេតុផលនៃការដកហូត៖...........................................................................

  ..........................................................................................................................

  ..........................................................................................................................
- ប្រភេទសារជាតុបង្កគ្រោះ (រូបវន្ត គីមី ជីវៈ និងការចម្លងចូល)៖.........................................

  ..........................................................................................................................
- ការឱ្យអនុសាសន៍ដល់អ្នកប្រើប្រាស់៖.......................................................................

  ..........................................................................................................................
- បញ្ហាដែលបានរកឃើញ៖......................................................................................

  ..........................................................................................................................
- ការវិភាគ៖........................................................................................................
- លទ្ធផលវិភាគ៖...................................................................................................
- ឯកសារលទ្ធផលវិភាគ៖.........................................................................................
- មេរោគបង្កជំងឺ៖..................................................................................................

  ..........................................................................................................................
- របាយការណ៍លម្អិតពីជំងឺ៖.....................................................................................
- អ្នកសម្រេចឱ្យដកហូត៖.........................................................................................
- ការសម្រេចម្ហូបអាហារដែលបានដកហូត៖
  - ស្នើសុំការកម្ទេចចោល៖

    ..................................................................................................................
  - ស្នើសុំការកែតម្រូវលើស្លាកសញ្ញា
  - ស្នើសុំការកែច្នៃសម្រាប់ទិសដៅប្រើប្រាស់ផ្សេងទៀត។